គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)
Committee For Free And Fair Elections In Cambodia (COMFREL)
ទីស្នាក់ការកណ្ដាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
P.O. Box 1145, Tel: (855) 23 884 150/12 942 019, Fax: (855) 23 883 750 E-mail: comfrel@online.com.kh, comfrel@comfrel.org or comfreladmin@online.com.kh, Site : www.comfrel.org
ខុមហ្វ្រែល COMFREL

គណៈកម្មាធិការនាយក
BOARD OF DIRECTORS

លោក ធុន សារាយ
Mr. THUN SARAY
ប្រធានគណៈកម្មាធិការនាយក
និងជាប្រធាន ADHOC

លោក សុក សំអឿន
Mr. SOK Sam Oeun
អនុប្រធានគណៈកម្មាធិការនាយក
និងជានាយក CDP

លោក យឹម ប៉ូ
Mr. YIM Po អគ្គលេខាធិការ
និង នាយក CCPCR

កញ្ញា ស៊ុន ចាន់សែន
Miss. SUN Chansen
ប្រធាន KYA

លោក មុំ សារិន
Mr. MOM Sarin
នាយក HRCDO

លោកស្រី ពឹង យក់ហៀប
Mr. PEUNG Yok Hiep
នាយិកា LAC

លោកស្រី ទីវ សារាយេត
Ms. TIV Sarayet
សហនាយិកា WMC

កញ្ញា សយ សារ៉ា វឌ្ឍនី
Miss. SAY Sara Vathany
នាយិកា CWCC

លោក គីម សុវណ្ណ
Mr. KIM Sovann
នាយក VIGILANCE

លោក អាង ច័ន្ទឫទ្ធិ
Mr. ANG Chanrith
នាយក KKKHRO

លោក យង់ គិមអេង
Mr. YONG Kim Eng
នាយក PDP-Center

លោក ភួង សិទ្ធិ
Mr. PHUONG Sith

លោក សឺន សែត
Mr. SEN Set

ស.ប្រ.ក.៣/លេខ ០៨/០៩ គ.ប.ស.យ/អ.ក

# សេចក្ដីប្រកាសព័ត៌មាន
# ស្ដីពី
# លទ្ធផលសិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍[១] នៃវិស័យអាទិភាពក្នុងខេត្ត រតនគិរី

*ភ្នំពេញ, ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៩*

ប្រជាពលរដ្ឋប្រមាណ ១១៩នាក់ មកពីស្រុកអូរយ៉ាដាវ ស្រុកបរកែវ ស្រុកកូនមុំ ស្រុកអូរជុំ និងក្រុងបានលុង នៅក្នុងខេត្តរតនគិរី និងមានសិក្ខាកាមស្ត្រីចូលរួមប្រមាណ ២៩% បានជួបជុំគ្នានៅក្នុងសិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តរតនគិរី នៅថ្ងៃទី១១ ខែមិថុនា ២០០៩។

អភិបាលរងខេត្តរតនគិរី ឯកឧត្ដម **ម៉ុម សារឿន** បានថ្លែងបើកសិក្ខាសាលាថា កម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលបានកំណត់វិធានការគោលនានា ដើម្បីអភិវឌ្ឍប្រទេសកម្ពុជា។ លោកក៏បានវាយតម្លៃខ្ពស់ដែរថា សិក្ខាសាលានេះបានផ្ដល់ឱកាសដល់ម្ចាស់ឆ្នោតធ្វើការបង្ហាញពីតម្រូវការរបស់ខ្លួនដល់មន្ត្រីជាប់ឆ្នោត ។

ជាលទ្ធផលម្ចាស់ឆ្នោតបានពិភាក្សាកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង ១០ ក្នុងខេត្តរតនគិរីដូចខាងក្រោម:

| លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអទិភាពទាំងដប់នៅក្នុងខេត្ត រតនគិរី |
|---|
| ១) រាជរដ្ឋាភិបាលត្រូវបង្កើតច្បាប់ប្រឆាំងអំពើពុករលួយឱ្យបាននៅយ៉ាងយូរត្រឹមថ្ងៃទី ០១ ខែ ០១ ឆ្នាំ ២០១០ ហើយត្រូវអនុវត្តច្បាប់នេះឱ្យមានប្រសិទ្ធិភាព ដោយជនណាប្រព្រឹត្តផ្ទុយនឹងច្បាប់ប្រឆាំងអំពើពុករលួយត្រូវផ្ដន្ទាទោសតាមច្បាប់ ដោយមិនរើសអើងទៅលើឋានៈបុណ្យសក្តិ ហើយត្រូវបង្កើតគណៈកម្មាធិការឯករាជ្យប្រឆាំងអំពើពុករលួយនៅដើមឆ្នាំ ២០១០ ដែរ ។ |
| ២) ចាប់ពីដើមឆ្នាំ ២០១០ សុំកុំយកកងកំលាំងប្រដាប់អាវុធជាតិ ទៅបំរើផលប្រយោជន៍ក្រុមឯកជនមួយក្ដាប់តូច ឬជនមានអំណាចប្រើប្រាស់គំរាមគំហែងប្រជាពលរដ្ឋ កម្មករ ហើយរាល់បញ្ហា ដែលកើតមានឡើងជាមួយប្រជាពលរដ្ឋ ត្រូវដោះស្រាយដោយសន្តិវិធី និងតាមច្បាប់ដែលមានស្រាប់ ។ |

[១] ការសន្យាណាដែលមានសូចនាករច្បាស់លាស់-អាចមានជាក់ស្ដែង អាចវាស់បានដូចជាការអនុម័តច្បាប់ ការបង្កើតស្ថាប័ន ឬជាសកម្មភាព ការអនុវត្តអ្វីមួយច្បាសលាស់ ដោយមានគោលដៅ ពេលវេលា ឬមានចំនួនកំណត់ច្បាស់លាស់ ឬមួយប្រៀបធៀបទៅនឹងអត្រាណាមួយច្បាស់លាស់។

| |
|---|
| ៣) ចង់ឱ្យមន្ត្រីកសិកម្មចុះបង្រៀនពី វិធីចិញ្ចឹមមាន់ ទា គោ ជ្រូក (១ ឆ្នាំ ៣ ដង  : ខែ ០១ ខែ ០៤ ខែ ០៩ ចាប់ពីឆ្នាំ ២០១០) នៅភូមិ ណងឡិ ឃុំអូរជុំ ស្រុកអូរជុំ ភូមិកំផ្លិញ ឃុំល្បាំង ស្រុកលំផាត់ ភូមិ ៣ ត្រពាំងក្រហម ស្រុកកូនមុំ ខេត្តរតនគីរី ។ |
| ៤) តុលាការមិនត្រូវយកប្រាក់ពីប្រជាពលរដ្ឋក្រីក្រដែលជាជនរងគ្រោះ នៅពេលពួកគាត់ដាក់ពាក្យបណ្តឹងចូលតុលាការ ចាប់ពីដើមឆ្នាំ ២០១០ តទៅ ហើយរាល់ការទៅសួរសុខទុក្ខអ្នកទោស ក្នុងពន្ធនាគារមិនត្រូវយកប្រាក់ឡើយចាប់ពីដើមឆ្នាំ ២០១០ តទៅ ។ |
| ៥) កសាងផ្លូវពីទីរួមស្រុកលំផាត់ ទៅភូមិបាតាង ឃុំបាតាង ស្រុកលំផាត់ ប្រភេទថ្នល់កៅស៊ូ ឱ្យរួចរាល់នៅឆ្នាំ ២០១១ ។ ថ្នល់ចាក់កៅស៊ូ ពីស្រុកបានលុង ទៅភូមិតាស៊ុយ ឃុំកាចាញ ឱ្យហើយ នៅឆ្នាំ ២០១១ ។ ស្រុកអូរយ៉ាដាវ ដល់ ភូមិគងធំ ឃុំបាតេ ឱ្យហើយត្រឹមឆ្នាំ ២០១១ (ក្រាល កៅស៊ូ) ។ ផ្លូវចូលភូមិពីផ្លូវធំ (ផ្លូវ ៧៨) ទៅភូមិ ឡាអិន ឃុំ តឺន ស្រុកកូនមុំ ប្រវែង ៥០០ ម៉ែត្រ ក្រាលគ្រោះ ឬកៅស៊ូ ឱ្យហើយត្រឹមឆ្នាំ ២០១១ ។ ផ្លូវគ្រោះ ឬកៅស៊ូ ពីផ្លូវជាតិចូលភូមិយ៉ឺន ឃុំកក់ ស្រុកបរកែវ  ប្រវែងប្រហែល ៥០០ ម៉ែត្រ ។ |
| ៦) សង់សាលារៀនបឋមសិក្សា ថ្មី (៦ បន្ទប់) នៅភូមិ តាអង ឱ្យរួចរាល់នៅឆ្នាំ ២០១១។ សង់សាលារៀនបឋមសិក្សា (៤ បន្ទប់) នៅភូមិកាឡៃសាពូន ឃុំភ្នំកុក ស្រុកវ៉ឺនសៃ និងសាលារៀនមតេយ្យមួយ នៅភូមិ ១ ឃុំកាចាញ ឱ្យរួចរាល់នៅឆ្នាំ ២០១២។ សង់សាលារៀនបឋមសិក្សា (៥ បន្ទប់) នៅភូមិសាលា ឃុំកក់ ស្រុកបរកែវ និងមណ្ឌលសុខភាព (សំណង់ថ្មប្រក់ក្បឿង) នៅឃុំ ត្រពាំងក្រហម ឱ្យរួចរាល់នៅឆ្នាំ ២០១២ និងមណ្ឌលសុខភាពនៅឃុំ តាអង ឱ្យហើយនៅឆ្នាំ ២០១១។ ជំរុញការកសាងផ្សារស្រុកកូនមុំ នៅឃុំត្រពាំងច្រេស (សំណង់ថ្ម) ឱ្យហើយនៅឆ្នាំ ២០១០។ |
| ៧) សុំអោយមន្ត្រីកសិកម្មចុះបង្រៀនរបៀបចិញ្ចឹមជ្រូក និងសុំពូជជ្រូកមួយចំនួន (បង្រៀន ៣ ដង ក្នុងមួយឆ្នាំ នៅខែ ០១ ខែ ០៤ ខែ ០៧) និងសុំពូជជ្រូកយ៉ក់ខ្សៀ ចំនួន ៦០ក្បាល (ញី ៤០ ឈ្មោល ២០) សម្រាប់ភូមិកាឡៃ សាពួន ភ្នំកុក ឃុំភ្នំកុក ស្រុកវ៉ឺនសៃ និងភូមិកាតេ ឃុំលុងខ្ញរ ស្រុកអូរយ៉ាដាវ ដោយសុំអោយមេភូមិជាអ្នកចែកអោយអ្នកដែលអត់ទាន់មាន ចាប់ពីឆ្នាំ ២០១០តទៅ។ |
| ៨) សុំអោយមន្ត្រីពេទ្យសត្វចុះចាក់ថ្នាំ (គោ ក្របី) ២ ដង ក្នុងមួយឆ្នាំ (ខែ០៦ និងខែ ១២) ។ មន្ត្រីចុះមានគ្នា ៣ នាក់ ចាក់នៅគ្រប់ស្រុក ចាប់ពីដើមឆ្នាំ ២០១០។ |
| ៩) សុំអោយបង្កើតរោងចក្រធុនតូច ចំនួន ៣ មានដូចជា រោងចក្រគ្រាប់ស្វាយចន្ទី រោងចក្រកែច្នៃម្សៅមី និងរោងចក្រកែច្នៃសណ្តែកសៀង នៅទីរួមខេត្តរតនគីរី យ៉ាងយូរឆ្នាំ ២០១២ ។ |
| ១០) សុំសាលាបឋមសិក្សាចំនួន ២ ខ្នង (មួយខ្នងនៅភូមិ ១ ក្រុមតាស៊ុយ ឃុំកាចាញ ស្រុកបានលុង) ។ មួយខ្នងទៀត នៅភូមិកងយុ ឃុំបាតេ ស្រុកអូរយ៉ាដាវ ឱ្យបានក្នុងឆ្នាំ ២០១០) ។ |

សិក្ខាសាលានេះត្រូវបានរៀបចំឡើងដោយ  គណៈកម្មាធិការខុមហ្វ្រែល  សហការជាមួយអង្គការអភិវឌ្ឍន៍  និងភាពជាដៃគូរក្នុងសកម្មភាព (DPA) និង មជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍ (CLEC) ដោយមានការចូលរួមពីម្ចាស់ឆ្នោតដែលតំណាងឱ្យសហគមន៍ព្រៃឈើ ដីធ្លី ... និងអង្គការមិនមែនរដ្ឋាភិបាលនានា អាជីវករ/ពាណិជ្ជករ មន្ត្រីរាជការ សិស្ស/ និស្សិត កសិករ។

សិក្ខាសាលាម្ចាស់ឆ្នោតនេះ  ជាគំនិតបង្កើតថ្មីមួយក្នុងគោលបំណងឱ្យប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតនៅតាមមណ្ឌលនីមួយៗ:

១) មានការយល់ដឹងពីកម្មវិធីនយោបាយនិងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលជាប់ឆ្នោតឆ្នាំ ២០០៨

២) ចូលរួមក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានា ដែលត្រូវការចាំបាច់ក្នុងមណ្ឌល (ខេត្ត) របស់ខ្លួន

៣) និង លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានាសម្រាប់មណ្ឌលនីមួយៗ ត្រូវបានចងក្រងជារបាយការណ៍ ដែលអាចឱ្យសិក្ខាកាមងាយចងចាំដើម្បីចូលរួមតាមដាន និងជម្រុញការអនុវត្តរបស់រាជរដ្ឋាភិបាល អ្នក-តំណាងរាស្ត្រ ក្រុមប្រឹក្សា/គណៈអភិបាលខេត្ត-រាជធានី ក្នុងការសម្រេចបានលក្ខខណ្ឌសន្ទស្សន៍នៃវិស័យទាំងនោះ។

*សម្រាប់ព័ត៌មានបន្ថែមៗសូមទាក់ទង:*

- លោក **ច័ន្ទ ដារិទ្ធ** អ្នកសម្របសម្រួលផ្នែកព័ត៌មានខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៨៤៦ ២១១
- លោក **សុខ ពិទូរ្យ** អ្នកសម្របសម្រួលស្តីទីផ្នែកអង្កេតខុមហ្វ្រែល ទូរស័ព្ទ: ០៨៩ ៥២៥ ៤៨៦